**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ៧៦៣......ប្រក.កសក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យក្រុមហ៊ុន VANNY BIO-RESEARCH (CAMBODIA) CORPORATION LTD បង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និង ស្រាវជ្រាវសត្វស្វាក្តាមយកកូននាំចេញ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញលិខិតលេខ ១២៨៨ សជណ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០១ របស់ទីស្តីការគណរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យក្រុមហ៊ុន VANNY Bio-Research (Cambodia) Corporation LTD បង្កើតកសិដ្ឋាន ស្រាវជ្រាវបង្កាត់ពូជស្វាក្តាមមួយកន្លែង

- បានឃើញពាក្យស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និងស្រាវជ្រាវសត្វស្វាក្ដាមកម្ពុជាយកកូននាំចេញរបស់ក្រុមហ៊ុន VANNY Bio-Research (Cambodia) Corporation LTD ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០០៤

## សម្រេច

**ប្រការ១** ៖ អនុញ្ញាតឱ្យលោក LAU MAN SANG, JAMES ប្រធានក្រុមហ៊ុន VANNY BIO-RESEARCH (CAMBODIA) CORPORATION LTD បង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និងស្រាវជ្រាវសត្វស្វាក្ដាមកម្ពុជាមួយកន្លែងដើម្បីយកកូននាំចេញ ដែលមានផ្ទៃដីទំហំ ៤,២០ ហិកតា ស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

**ប្រការ២** ៖ សាមីកសិដ្ឋានដែលបានអនុញ្ញាតតាមប្រការ១ខាងលើ ត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

ក-ត្រូវមានប្រព័ន្ធអេកូឡូស៊ីសមស្របនឹងលំនៅដ្ឋានកំណើតនៃសត្វស្វាក្ដាមដែលយកមកចិញ្ចឹម ។

ខ-ត្រូវធ្វើរបងហ៊ុមព័ទ្ធបរិវេណកសិដ្ឋាន ។

គ-ត្រូវរៀបចំទ្រុងឱ្យមានទំហំទូលាយតាមបច្ចេកទេសត្រឹមត្រូវអាចឱ្យសត្វធ្វើចលនាដោយសុវត្ថិភាព ។

ឃ-ត្រូវមានអនាម័យគ្រប់ពេលវេលាដើម្បីធានាដល់សុខុមាលភាពសត្វ និង មិនប៉ះពាល់បរិស្ថានជុំវិញ ។

ង-ត្រូវផ្ដល់ចំណីអាហារដែលប្រកបដោយគុណភាពដើម្បីរក្សាបានសុខភាព និងការបន្តពូជ ។

ច-ត្រូវមានអ្នកឯកទេសបសុពេទ្យ ថ្នាំពេទ្យ ទូរក្សាថ្នាំពេទ្យ បន្ទប់ជួយសង្គ្រោះ ដើម្បីធានាការព្យាបាលសត្វស្វាក្ដាមជាប្រចាំ ។

ឆ-ការនាំសត្វស្វាក្ដាមចូលកសិដ្ឋាន ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានលិខិតអនុញ្ញាតដឹកជញ្ជូនពីសមត្ថកិច្ចជំនាញ ។

ជ-ការនាំចេញកូនស្វាក្ដាមត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវមានលិខិតនាំចេញពីសមត្ថកិច្ចជំនាញ ។

ឈ-ត្រូវសំរួលដល់មុខនាទីអាជ្ញាធរមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញ-ចូលធ្វើការត្រួតពិនិត្យសកម្មភាពកសិដ្ឋានគ្រប់ពេលវេលា ។

ញ-កសិដ្ឋានចិញ្ចឹមសត្វស្វាក្ដាម ត្រូវមានសៀវភៅបញ្ជីតាមដានសត្វស្វាក្ដាមចេញ-ចូលច្បាស់លាស់ ។

ដ-សត្វស្វាក្ដាមមេ បា និងកូនគ្រប់ជំនាន់ ត្រូវរៀបចំឱ្យមានពាក់ផ្លាកលេខសំគាល់ច្បាស់លាស់ ។

ឋ-ត្រូវទទួលខុសត្រូវលើគ្រប់បទល្មើសដែលកើតមានក្នុងបរិវេណកសិដ្ឋានសត្វស្វាក្ដាមរបស់ខ្លួន ។

ឌ-ការប្ដូរឈ្មោះ ឬផ្ទេរកសិដ្ឋានសត្វស្វាក្ដាមពីអ្នកគ្រប់គ្រងមួយទៅមួយទៀត ត្រូវហាមឃាត់ជាដាច់ខាត ។

<u>ប្រការ៣</u> ៈ ប្រកាសអនុញ្ញាតឱ្យបង្កើតកសិដ្ឋាននេះ នឹងត្រូវទុកជានិរាករណ៍ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីដែលយល់ឃើញថាបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរមានលក្ខណៈមិនរាងចាល បន្ទាប់ពីបានទទួលការព្រមាន ផាកពិន័យជាបន្តបន្ទាប់ ។

<u>ប្រការ៤</u> ៈ អគ្គនាយកនៃក្រសួង អគ្គាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកណ្តាល និង ម្ចាស់កសិដ្ឋានសាមីត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៤

រដ្ឋមន្ត្រី

ចាន់-សារុន

<u>**កន្លែងទទួល:**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-អាជ្ញាធរគ្រប់គ្រងសាយតេសកម្ពុជា
-សាលាខេត្តកណ្តាល

"<u>ដើម្បីជូនជ្រាប</u>"

-ដូចប្រការ៤

"<u>ដើម្បីអនុវត្ត</u>"

-ឯកសារ-កាលប្បវត្តិ